ក្រសួងសុខាភិបាល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី និងមានករណីជាសះស្បើយ ចំនួន ០២នាក់
# នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស** ៖ គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ មានដូចតារាងខាងក្រោមនេះ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣៨៧ | ១០០ | ២៨៧ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៨៧ | ៦៧ | ២០ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៤៧៤** | **១៦៧** | **៣០៧** | អ្នកឆ្លងថ្មី៖ ០នាក់ |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣៧៣ | ៩៣ | ២៨០ | អ្នកជាសះស្បើយថ្មី៖០នាក់ |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៨៣ | ៦៣ | ២០ | អ្នកជាសះស្បើយថ្មី៖**០២នាក់** |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **៤៥៦** | **១៥៦** | **៣០០** | អ្នកជាសះស្បើយថ្មី៖**០២នាក់** |
| ៣. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |
| | ៣.១មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន | ១១ | ០៥ | ០៦ | |
| | ៣.២. មន្ទីរពេទ្យបង្អែក ខេត្តប៉ៃលិន | ០៣ | ០៣ | ០ | |
| | ៣.៣.មន្ទីរពេទ្យបង្អែក ខេត្តបន្ទាយមានជ័យ | ០១ | ០១ | ០ | |
| | ៣.៤. មន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង | ០ | ០ | ០ | |
| | ៣.៥.មន្ទីរពេទ្យបង្អែក ខេត្តឧត្តរមានជ័យ | ០ | ០ | ០ | |
| | ៣.៦.មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ០២ | ០១ | ០១ | |
| | ៣.៧. មណ្ឌលសុខភាពចាក់អង្រែ | ០១ | ០១ | ០ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **១៨** | **១១** | **០៧** | |

**២. ព័ត៌មានប្រចាំថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១**

**ក. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖** នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០២១

**ខ. មានករណីជាសះស្បើយ ៖** សរុបចំនួន ០២នាក់ ដែលជាពលករធ្វើដំណើរមកពីប្រទេសថៃ



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

- ស្ត្រីជនជាតិខ្មែរ អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ បានធ្វើដំណើរមកពីប្រទេសថៃ មកដល់កម្ពុជានៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១ ។

- ស្ត្រីជនជាតិខ្មែរ អាយុ ៤០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានធ្វើដំណើរមកពីប្រទេសថៃ មកដល់កម្ពុជានៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១។

**សូមកត់សម្គាល់ថា៖** បុគ្គលទាំង ០២នាក់ខាងលើ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុស កូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែក ខេត្តបន្ទាយមានជ័យ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ចិត្ត** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ១១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១